# សុន្ទរកថា

## ឯកឧត្តម ថាច់ សេដ្ឋា អតីតសមាជិកព្រឹទ្ធសភា

## នៃព្រះរាជាណាចក្រកម្ពុជា

## និងជានាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

## ក្នុងទិវាកាន់ទុក្ខទី៥៨ឆ្នាំ

## នៃថ្ងៃអាណានិគមបារាំងកាត់ទឹកដីកម្ពុជាក្រោម

## ឱ្យអាជ្ញាធរអាណានិគមវៀតណាម

## (០៤/០៦/១៩៤៩ ~ ០៤/០៦/២០០៧)

លេខ.............................. ស.ខ.ក.ក.

## <u>សុន្ទរកថា</u>

### ឯកឧត្តម ថាច់ សេដ្ឋា អតីតសមាជិកព្រឹទ្ធសភា នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម ក្នុងឱកាសបុណ្យរាប់បាត្រព្រះសង្ឃ១៩៤៩អង្គ និងប្រារព្ធខួបគំរប់ទី៥៨ឆ្នាំ នៃទិវាកាន់ទុក្ខជាតិខ្មែរ ថ្ងៃអាណានិគម បារាំងកាត់ទឹកដីខ្មែរកម្ពុជាក្រោមឱ្យវៀតណាម នៅសួនច្បារមុខវត្តបទុមវតី ភ្នំពេញ (០៤/០៦/១៩៤៩-០៤/០៦/២០០៧)

- សូមនមស្សការចំពោះប្រជុំបីនៃព្រះត្រៃរតន៍
- សូមគោរព និងក្រាបថ្វាយបង្គំ ព្រះវិញ្ញាណក្ខន្ធវីរសមណៈ ព្រះវិញ្ញាណក្ខន្ធវីរមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស វីរនារីខ្មែរស្នេហាជាតិដ៏ខ្ពង់ខ្ពស់
- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
- សូមថ្វាយបង្គំ**អ្នកអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស** ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃ**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាអធិបតីដ៏ខ្ពង់ខ្ពស់ ។
- សូមគោរពព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសជាតិ អន្តរជាតិទាំងអស់ជាទីស្នេហា

ថ្ងៃនេះ សហគមន៍ខ្មែរកំណើតកម្ពុជាក្រោមនៅពាសពេញពិភពលោក និងនៅព្រះរាជាណាចក្រកម្ពុជាប្រារព្ធខួបគំរប់៥៨ឆ្នាំ ថ្ងៃអាណានិគមបារាំងកាត់ទឹកដី***កម្ពុជាក្រោម*** ឱ្យអាជ្ញាធរអាណានិគមវៀតណាម(០៤.០៦.១៩៤៩-០៤.០៦.២០០៧) ដើម្បីសំដែងនូវការឈឺចាប់ និងទុក្ខកង្វល់យ៉ាងក្រៀមក្រំបំផុតចំពោះទង្វើដ៏អយុត្តិធម៌របស់អាណានិគមនិយមបារាំង និងសំដែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធវីរសមណៈ វីរព្រះមហាក្សត្រនិងវីរបុរស-នារីខ្មែរស្នេហាជាតិទាំងអស់ ដែលបានបូជាព្រះកាយ និងបូជាកាយក្នុងបុព្វហេតុជាតិ សាសនា និងទឹកដីខ្មែរទាំងមូល ពិសេសពូជសាសន៍ សាសនា និងទឹកដីខ្មែរកម្ពុជាក្រោម ។

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ ជាទិវាដែលប្រជាជាតិខ្មែរឈឺចាប់បំផុតក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ដោយសារអាណានិគមនិយមបារាំងបានធ្វើច្បាប់ដ៏ទុរយសលេខ ៤៩-៧៣៣ អនុម័តយល់ព្រមដោយសភាបារាំងនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ កាត់ទឹកដីកម្ពុជាក្រោម ដែលមានទំហំ ៦៨,៩៦៥ គីឡូម៉ែត្រក្រឡា (បច្ចុប្បន្នមានប្រជារាស្ត្រខ្មែរជាង

១៣លាននាក់) ឱ្យអាជ្ញាធរអាណានិគមវៀតណាមត្រួតត្រាបន្តរហូតដល់សព្វថ្ងៃ ដោយមិនបានសួរមតិប្រជារាស្ត្រខ្មែរម្ចាស់ស្រុកឬថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រខ្មែរឡើយ ។ ច្បាប់នេះមានសេចក្តីទាំងស្រុងជាភាសាបារាំងដូចតទៅនេះ

Loi N°49-733 du 4 Juin 1949 modifieant le statut de la Cochinechine dans l'Union française.

Aprés avis de l'Assemblée nationale de l'Union française,
L'Assemblée nationale et le Conseil de la République ont délibéré,

L'Assemblée nationale a adopté,

Le Président de la République promulgue le loi don't la teneur suit:

Art. 1er – Dans le cadre fixé á L'article 60 le la Constitution de la Républicque francaise et aprés l'avis émis, dans sa séance du 23 april 1949, par l'Assemblée territoriale de Cochinchine, le statut de la Cochinchine est modifié dans les conditions prévues á l'article ci-aprés.

Atr. 2.- Le territoire de la Cochinchine est rattaché á l'Etat associé du Viet-Nam suivant les termes de la declaration commune du 5 juin 1948 et de la declaration du Gouvernement française du 19 août 1948.

La Cochinchine cesse en conséquesnce d'avoir le statut de teritoire d'outre-mer.

Art. 3- En cas de changement du statut du Viet-Nam, le statut de la Cochinchine fera l'objet d'une nouvelle deliberation des assemblées prévues á l'article 75 de la Constitution (Titre VIII: De l'Union française).

La présente loi sera execute comme loi de l'Etat.
Fait á Toulon, le 4 Juin 1949.

VINCENT AURIOL
1er le Président de la République:

Le president du conseil des ministres,
HENRI QUEUILLE.

Le Ministére de la France d'outre-mer,
PAUL COSTE-FLORET.

ប្រែជាភាសាខ្មែរ (ក្រៅផ្លូវការ) ថា:

ច្បាប់លេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩

យោងមតិពីរដ្ឋសភានៃសហភាពបារាំង

រដ្ឋសភា និងក្រុមប្រឹក្សានៃសាធារណរដ្ឋបារាំង បានសម្រេច

រដ្ឋសភានៃសាធារណរដ្ឋបារាំង បានអនុម័ត

ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ប្រកាសច្បាប់ដូចតទៅនេះ :

មាត្រា១ - ក្នុងក្របខណ្ឌមាត្រា៦០ នៃធម្មនុញ្ញសាធារណរដ្ឋបារាំង និងតាមមតិរបស់សភាកូសាំងស៊ីន នាសម័យប្រជុំថ្ងៃទី២៣ មេសា ១៩៤៩ លក្ខន្តិកៈទឹកដីកូសាំងស៊ីនបានត្រូវកែប្រែតាមមាត្រាដូចមានចែងខាងក្រោម ។

មាត្រា២ - ទឹកដីកូសាំងស៊ីនត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម យោងតាមសេចក្តីប្រកាសរួមកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៤៨ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំង កាលពីថ្ងៃទី១៩ សីហា ១៩៤៨ ។ ទឹកដីកូសាំងស៊ីន ឈប់ស្ថិតនៅក្នុងលក្ខន្តិកៈជាទឹកដីឯនាយសមុទ្ររបស់បារាំងទៀតហើយ ។

មាត្រា៣ - ក្នុងករណីដែលលក្ខន្តិកៈប្រទេសវៀតណាមត្រូវកែប្រែ លក្ខន្តិកៈកូសាំងស៊ីននឹងត្រូវទុកជាកម្មវត្ថុនៃការសម្រេចរបស់សភាខាងលើ ដូចមានចែងក្នុងមាត្រា៧៥ នៃរដ្ឋធម្មនុញ្ញ ( ជំពូក VIII : សហភាពបារាំង) ។

ច្បាប់នេះ នឹងត្រូវអនុវត្តដូចជាច្បាប់រដ្ឋ ។

ធ្វើនៅទូឡុង ថ្ងៃទី០៤ មិថុនា ឆ្នាំ១៩៤៩

| | | |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| ***វ៉ាំងសង់ អុរីយ៉ូល*** | ***ហង់រី កើយ*** | ***ប៉ូល កូស្ត-ផ្លូរ៉េត*** |
| ប្រធានាធិបតី | នាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ |

ផ្តើមចេញពីទង្វើរបស់អាណានិគមនិយមបារាំង បានពុះចែកបំបែកទឹកដីខ្មែរបង្វែរឱ្យអាជ្ញាធរអាណានិគមវៀតណាមនេះ សោកនាដកម្មដ៏សែនឈឺចាប់រាប់មិនអស់ បានកើតឡើងចំពោះប្រជារាស្ត្រ និងព្រះសង្ឃខ្មែរដែលជាម្ចាស់ទឹកដីគ្មានពេលស្រាកស្រាន្ត ។ ទឹកភ្នែកក្លាយជាឈាម ឪពុកព្រាត់កូន ជីដូនព្រាត់ចៅ ប្តីព្រាត់ប្រពន្ធ គ្រូព្រាត់សិស្ស ។ សម្រែកឈឺចាប់ លាយឡំដោយសម្រែកដង្ហោយហៅរកជំនួយ ជួយសង្គ្រោះរំដោះទុក្ខភ័យ បានលាន់កងរំពងពាសពេញទឹកដីកម្ពុជាក្រោម ប៉ុន្តែមិនដែលបានចម្លើយអ្វីក្រៅពីភាសាសម្លុតគំរាម ការធ្វើទារុណកម្ម កាប់សម្លាប់បន្ថែមតែប៉ុណ្ណោះ ។ ភាពតក់ស្លុតរន្ធត់ចិត្តបំផុតនោះ គឺនៅពេលបានឃើញអាជ្ញាធរអាណានិគមវៀតណាមចាប់ព្រះសង្ឃខ្មែរ ដែលជាព្រះឧបជ្ឈាយ៍ ព្រះចៅអធិការ ព្រះពហុសូត្រ គ្រូអាចារ្យ ឧបាសក ឧបាសិកា ដែលជាបញ្ញវន្តខ្មែរដាក់ខ្នោះបញ្ចូលគុកដោយធ្វើទារុណកម្មយ៉ាងវេទនាមិនអាចពណ៌នាបាន ។ ទំនៀមទំលាប់ សិល្បៈ វប្បធម៌ ប្រពៃណីខ្មែរត្រូវរងការបំផ្លិចបំផ្លាញយ៉ាងព្រៃផ្សៃ ។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

គណៈអធិបតីជាទីគោរព

បងប្អូនរួមឈាមជាទីស្នេហា

"គ្មានអ្វីឈឺចាប់ជាងការបាត់បង់ទឹកដី និងក្លាយខ្លួនជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួនទេ" ។ អាជ្ញាធរអាណានិគមវៀតណាមបានប្រើប្រាស់គ្រប់ល្បិចកលក្នុងការធ្វើបាបសម្លុតគំរាម កាប់សម្លាប់ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរ



www.khmerkromngo.org

កម្ពុជាក្រោម ដើម្បីបង្ខំប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោមឱ្យគោរពតាមនយោបាយវៀតណាមូបនីយកម្ម។ គ្រប់របបនយោបាយក្នុងប្រទេសវៀតណាម តែងតែចិញ្ចឹមចិត្តអនុវត្តនយោបាយប្រល័យពូជសាសន៍ខ្មែរជានិច្ច ដោយមិនកោតក្រែងវអែងសាធារណមតិជាតិ-អន្តរជាតិឡើយ។ នៅក្នុងឆ្នាំ១៨១៥-១៨១៩ អាជ្ញាធរអាណានិគមវៀតណាមបានកេណ្ឌប្រជារាស្ត្រខ្មែររាប់ពាន់នាក់ទៅសម្លាប់ក្នុងការដ្ឋានជីកព្រែកវិញតេ។

នៅឆ្នាំ១៨០៦-១៨៤១ យួនយកក្បាលខ្មែរធ្វើមុមចង្ក្រានដាំតែអុង (**ដាំតែឱ្យលោកធំយួន**) និងកាប់សម្លាប់ប្រជារាស្ត្រខ្មែរ កែប្រែទំនៀមទំលាប់ប្រពៃណីខ្មែរ និងកំទេចវត្តអារាមជាដើម។

ឆ្នាំ១៩៤៥ យួនកេណ្ឌប្រជារាស្ត្រខ្មែររាប់ម៉ឺននាក់ដាក់ក្នុងជង្រុកស្រូវនៅខេត្តឃ្លាំង និងខេត្តលលាវ រួចចាក់សាំងដុតទាំងរស់។

ឆ្នាំ១៩៥៧-១៩៦០ យួនបង្ខំប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោមឱ្យផ្លាស់ប្តូរទំនៀមទំលាប់ទៅតាមរបៀបយួន។ ព្រះសង្ឃខ្មែរត្រូវកោរសក់ទុកចិញ្ចើម ស្លៀកពាក់អាវដៃធំពណ៌ឈាមជ្រូក សូត្រធម៌ត្រូវគោះត្រដោក។ ប្រជារាស្ត្រខ្មែរត្រូវទុកសក់បួង ស្លៀកពាក់ខោអាវតាមបែបយួន និងបំបាត់កម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរចេញពីសាលារដ្ឋទាំងស្រុង។

ឆ្នាំ១៩៦៣-១៩៧៥ យួនប្តូរសញ្ជាតិខ្មែរទៅជាវៀតណាមកំណើតខ្មែរ ( nguoi viet goc miên) ដុតបំផ្លាញវត្តអារាម និងចាប់ព្រះសង្ឃយកទៅធ្វើទាហាន។

ឆ្នាំ១៩៧៦ យួនកេណ្ឌព្រះសង្ឃ និងប្រជារាស្ត្រខ្មែររាប់សែននាក់ទៅជីកព្រែក ០៣ កុម្ភៈ (រំលឹកថ្ងៃកំណើតបក្សកុម្មុយនីស្តឥណ្ឌូចិន) ដែលមានជំរៅ៩ម៉ែត្រ បាតក្រោម១២ម៉ែត្រ មាត់លើ៣០ម៉ែត្រ យ៉ាងធ្ងន់ធ្ងរបំផុត។

ឆ្នាំ១៩៨៥-១៩៨៧ យួនចាប់ព្រះសង្ឃ អ្នកប្រាជ្ញបញ្ញវន្តខ្មែរចំនួន៤,២៤៨នាក់ ដាក់ពន្ធនាគារ និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃបំផុត ក្នុងនោះរាប់រយនាក់បានស្លាប់ក្នុងពន្ធនាគារ និងខ្លះទៀតពិការនិងវិកលចរិតរហូតដល់សព្វថ្ងៃ។ សាលារៀនភាសាខ្មែរតាមវត្តអារាម ត្រូវរៀនតាមកម្មវិធីដែលអាជ្ញាធរអាណានិគមវៀតណាមបានកំណត់. គម្ពីរដីកា សាស្ត្រាស្លឹករឹត ត្រូវយួនដុតបំផ្លាញស្ទើរគ្មានសល់។

ចាប់ពីឆ្នាំ១៩៧៦រហូតមកទល់បច្ចុប្បន្ន ព្រះសង្ឃខ្មែរត្រូវបង្ខំឱ្យធ្វើស្រែចំការ ចិញ្ចឹមសត្វពាហនៈ និងចិញ្ចឹមត្រីដូចគ្រហស្ថ។

ឆ្នាំ២០០៧ ក្នុងខែកុម្ភៈ និងខែមេសា យួនបានចាប់ព្រះសង្ឃខ្មែរចំនួន១៦អង្គសម្រាតស្បង់ចីពរផ្សឹក ហើយបានកាត់ទោសចំនួន៥អង្គ ដាក់ពន្ធនាគារពី២ឆ្នាំទៅ៤ឆ្នាំ ព្រះសង្ឃខ្លះត្រូវបង់ពិន័យជាប្រាក់ចំនួន $100 (មួយរយដុល្លាសហរដ្ឋអាមេរិក) ឱ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម។

ទោះបីជាអាជ្ញាធរវៀតណាមបានប្រើគ្រប់ល្បិចកលធ្វើបាប កាប់សម្លាប់ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម ដើម្បីបង្ខំឱ្យគោរពតាមនយោបាយវៀតណាមូបនីយកម្មយ៉ាងណា ក៏ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម មិនព្រមបោះបង់សញ្ជាតិខ្មែរ ទំនៀមទំលាប់ វប្បធម៌ ព្រះពុទ្ធសាសនារបស់ខ្លួនចូលជាតិសាសន៍យួនដែរ គឺដាច់ខាតនៅតែរក្សាអត្តសញ្ញាណជាតិជាខ្មែរជាដដែល ហើយបានចាត់ទុកទឹកដីកម្ពុជាក្រោមជាកម្មសិទ្ធិស្របច្បាប់របស់ប្រជារាស្ត្រខ្មែរ។ ទង្វើ


www.khmerkromngo.org

របស់អាណានិគមបារាំងជាទង្វើខុសច្បាប់និងអយុត្តិធម៌បំផុតចំពោះប្រជារាស្ត្រខ្មែរម្ចាស់ស្រុក ។ ការត្រួតត្រារបស់អាជ្ញាធរអាណានិគមវៀតណាមសព្វថ្ងៃ គ្រាន់តែជាការបន្តវេនពីអាណានិគមបារាំងប៉ុណ្ណោះ ។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

គណៈអធិបតីជាទីគោរព

បងប្អូនជនរួមជាតិជាទីស្នេហា

ដើម្បីចៀសវាងការបកស្រាយខុសពីការពិតនៃប្រវត្តិសាស្ត្រទឹកដីខ្មែរកម្ពុជាក្រោម អំពីអត្តសញ្ញាណប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ហើយដោយសារបច្ចុប្បន្នអាជ្ញាធរអាណានិគមវៀតណាម កំពុងតែក្រឡៃប្រវត្តិសាស្ត្រទឹកដីខ្មែរកម្ពុជាក្រោមផងនោះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំបាទ សូមព្រះអនុញ្ញាត អនុញ្ញាត ប្រគេន ថ្វាយនិងជំរាបជូនព្រះថេរានុត្ថេរៈ គណៈអធិបតី និងជនរួមជាតិទាំងអស់នូវប្រវត្តិសង្ខេបនៃទឹកដីកម្ពុជាក្រោមដូចតទៅ:

កម្ពុជាក្រោមជាអតីតទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅខាងកើតឆៀងខាងត្បូងនៃព្រះរាជាណាចក្រកម្ពុ-ជាបច្ចុប្បន្នជាចំណែកមួយនៃទឹកដីសាធារណរដ្ឋសង្គមនិយមវៀតណាម ។ កម្ពុជាក្រោមមានប្រវត្តិសាស្ត្រជាង២០០០ឆ្នាំមុនគ្រិស្តសករាជ ។ ដូចគ្នានៅព្រះរាជាណាចក្រកម្ពុជា ប្រជារាស្ត្រខ្មែរដែលមកតាំងទីលំនៅលើទឹកដីកម្ពុជាក្រោមមុនគេនៅតំបន់អាស៊ីអាគ្នេយ៍ ។ តាមឯកសារប្រវត្តិសាស្ត្របានសរសេរថា ទីក្រុងព្រៃនគរដែលយួនហៅថា សៃហ្គនបច្ចុប្បន្នជាទីក្រុងហូជីមិញបច្ចុប្បន្ន ជាអតីតរាជធានីដំបូងបង្អស់របស់ខ្មែរ ដែលព្រះមហាក្សត្រខ្មែរទាំងឡាយបានគង់ប្រថាប់ តាំងពីឆ្នាំ២៨៩មុនគ្រិស្តសករាជ។ ប៉ុន្តែពីសតវត្សរ៍ទី១ដល់ទី៦ ទឹកដីដែលបង្កើតទៅជាព្រះរាជាណាចក្រកម្ពុជា ត្រូវបានចែកចេញជាពីរផ្នែកគឺ ផ្នែកដែនដីទំនាបលិចទឹក (**កម្ពុជាក្រោម**) ហៅថាហ្វូណន ។ ផ្នែកខាងលើអាងមធ្យមទន្លេមេគង្គ (កម្ពុជា) ហៅថា **ចេនឡាឬនគរភ្នំ**។ នៅពាក់កណ្តាលសតវត្សរ៍ទី៦ ព្រះអង្គម្ចាស់ភវវរ្ម័នក្នុងសន្តិវង្ស ហ្វូណន ជាព្រះរាជនត្តារុទ្រវរ្ម័នបានរៀបអភិសេកជាមួយព្រះអង្គម្ចាស់ក្សត្រីមួយអង្គនៅនគរចេនឡានៃសន្តតិវង្សទ្រុឌវរ្ម័ន ។ ក្រោយពីបានរៀបអភិសេករួចហើយ ព្រះបាទភវវរ្ម័នបានឡើងសោយរាជ្យនៅនគរចេនឡាក្នុងឆ្នាំ៥៥០ ។ ព្រះអង្គបានបង្រួបបង្រួម នគរទាំងពីរ (ហ្វូណននិងចេនឡា) ឱ្យទៅជានគរតែមួយគឺ"**កម្ពុជា**" ។ ដូចនេះព្រះបាទភវវរ្ម័នជាស្ថាបនិកនៃព្រះរាជាណាចក្រកម្ពុជាដ៏ពិតប្រាកដ ។

តាមការសិក្សាស្រាវជ្រាវរបស់ប្រវត្តិវិទូនិងបុរាណវិទូបានកត់ត្រាថា នៅសតវត្សរ៍ទី២-៣-៤-៥ កម្ពុជាមានកំពង់ផែសេដ្ឋកិច្ចដ៏សំខាន់មួយនៅអូរកែវ ឬអុកកែវ ហើយជារាជធានីនៃនគរហ្វូណន។ អូកែវបច្ចុប្បន្នជាកូនភ្នំតូចមួយមានរាងចតុកោណកែង មានបណ្តោយ៣គីឡូម៉ែត្រ ទទឹង១,៥០គីឡូម៉ែត្រ ស្ថិតនៅខាងត្បូងភ្នំបាថេ ក្នុងខេត្តពាមបន្ទាយមាស កម្ពុជាក្រោម (វៀតណាមហៅថា ហាទៀង) ។ ក្រៅពីនេះនៅមានសក្ការៈវត្ថុជាច្រើន ដូចជាព្រះពុទ្ធរូបមុនសម័យអង្គរ ព្រះសិវៈ ព្រះនារាយណ៍ និងវិហារព្រះពុទ្ធសាសនាជាដើម ដែលមានចំណាស់រាប់ពាន់ឆ្នាំ និងសិលាចារឹកជាដើមនៅពាសពេញទឹកដីកម្ពុជាក្រោម ។

បើសំអាងលើផែនទីវិញ រិតតែបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជាក្រោមជាទឹកដីរបស់ខ្មែរមិនអាចប្រកែកបានថែមទៀត ផែនទីទាំងនោះមានជាអាទិ៍

១- ផែនទីឥណ្ឌូចិននៅសតវត្សរ៍ទី៧ និងទី៨

២- ផែនទីឥណ្ឌូចិនគូរដោយជនជាតិព័រទុយហ្គាល់ បោះពុម្ពផ្សាយឆ្នាំ១៥៨០

៣- ផែនទីឥណ្ឌូចិន ឥណ្ឌាខាងកើត ស្តីពីផែនទីភូមិសាស្ត្រ Urtelina នៅឆ្នាំ១៥៩៣ របស់ប្រទេសកម្ពុជា

៤- ផែនទីឥណ្ឌាខាងកើត ស្តីពីសៀវភៅផែនទីភូមិសាស្ត្រ Morentor ឆ្នាំ១៦២៨

៥- ផែនទីឥណ្ឌូចិនបោះពុម្ពផ្សាយនៅឆ្នាំ១៦៣៨

៦- ផែនទីរបស់លោក Père Alexzandre de Rhodes ឆ្នាំ១៦៥០

៧- ផែនទីរាជាណាចក្រសៀម បោះពុម្ពផ្សាយនៅឆ្នាំ ១៧១៤

៨- ផែនទីឥណ្ឌូចិនរបស់លោក Guen deville ឆ្នាំ១៧១៣-១៧១៩

៩- ផែនទីឥណ្ឌូចិនគូរដោយលោក Robert ឆ្នាំ១៧១៧

១០- ផែនទីឥណ្ឌូចិនគូរដោយលោក Durville បោះពុម្ពឆ្នាំ១៧៩៥

១១- ផែនទីប្រទេសឥណ្ឌានៅខាងនាយទន្លេគង្គា (Gange )គូរឡើងសំរាប់ប្រវត្តិសាស្ត្រទូទៅរបស់អ្នកដំណើរ La Harpe

១២- ផែនទីឥណ្ឌូចិន បោះពុម្ពផ្សាយនៅឆ្នាំ១៨៥០ ។

ផែនទីទាំងនេះ បានបង្ហាញយ៉ាងច្បាស់ថា កម្ពុជាក្រោម ជាទឹកខ្មែរយ៉ាងពិតប្រាកដ ។

កម្ពុជាក្រោមមានវិសាលភាព ៦៨,៩៦៥ គីឡូម៉ែត្រក្រឡា មាន១៧១ ស្រុក, ១៣៦៨ឃុំ មាន១៤,៧៧៨ភូមិ និងមានប្រជារាស្ត្រខ្មែររស់នៅជាង១៣លាននាក់, វត្តអារាមព្រះពុទ្ធសាសនាចំនួន៥៦៧វត្ត និងព្រះសង្ឃជាង២០,០០០អង្គ; ប្រជារាស្ត្រខ្មែរ៩៩ភាគរយ គោរពព្រះពុទ្ធសាសនា ។

ក្នុងការរុករានឈ្លានពានទន្ទ្រានត្រួតត្រាទឹកដីខ្មែរ និងក្រោយថ្ងៃអាណានិគមនិយមបារាំងបានកាត់ទឹកដីកម្ពុជាក្រោមនៅថ្ងៃទី០៤-០៦-១៩៤៩ ឱ្យអាណានិគមវៀតណាមត្រួតត្រាបន្ត, អាជ្ញាធរអាណានិគមវៀតណាមមិនដែលភ្លេចនយោបាយវៀតណាមូបនីយកម្មមកលើប្រជារាស្ត្រខ្មែរម្ចាស់ស្រុកម្តងណាឡើយ ។

ដោយមិនអាចស៊ូទ្រាំឈរមើលទង្វើដ៏អសីលធម៌ ព្រៃផ្សៃរបស់ពួកអាណានិគមវៀតណាម មកលើប្រជារាស្ត្រនិងព្រះសង្ឃខ្មែរ លោកឧកញ៉ា **សឺន គុយ** ចៅហ្វាយខេត្តព្រះត្រពាំង រួមជាមួយសហការីជំនិត មានជាអាទិ៍ លោកតា ម៉ង់ ម៉ឺនឯក, ទេសា សោម និងមនោ រស់ជាដើម បានដឹកនាំប្រជារាស្ត្រខ្មែរកម្ពុជាក្រោមប្រយុទ្ធបណ្តេញអាណានិគមវៀតណាមចេញពីទឹកដីកម្ពុជាក្រោមយ៉ាងខ្លាំងក្លាបំផុត ។ ប៉ុន្តែការតស៊ូមិនបានទទួលជោគជ័យ ដោយសារពួកយួនបានបញ្ជូនកងទ័ពយ៉ាងច្រើនមកពីគ្រប់ទិសទី ដើម្បីទប់ទល់ជាមួយចលនាតស៊ូរបស់ខ្មែរ ដែលដឹកនាំដោយមហាវីរ បុរស **សឺន គុយ** ។ស្ថិតនៅចំពោះមុខស្ថានភាពកងទ័ពអាណានិគមវៀតណាមកាន់តែបង្កើន សកម្មភាពកាប់សម្លាប់ប្រជារាស្ត្រខ្មែរគ្មាន

ត្រាប្រណី វត្តអារាមត្រូវដុតបំផ្លាញគ្រប់ទិសទីដែលចលនាតស៊ូដឹកនាំដោយលោក មិនអាចទប់ទល់បាន លោកឧកញ៉ា **សឺន គុយ** មេទ័ពដ៏កំពូលរូបនេះ បានសំរេចចូលខ្លួនចរចាជាមួយអាជ្ញាធរអាណានិគមវៀតណាម ដើម្បីឱ្យអាជ្ញាធរអាណានិគមវៀតណាមបញ្ឈប់ការកាប់សម្លាប់ប្រជារាស្ត្រខ្មែរបញ្ឈប់ការដុតបំផ្លាញវត្តអារាម បញ្ឈប់ការរំលាយវប្បធម៌អក្សរសាស្ត្រខ្មែរ ដោយលោកសុខចិត្តឱ្យអាជ្ញាធរអាណានិគម វៀតណាមកាត់កទាំងរស់ ជាថ្នូរនឹងការរក្សាទុកពូជសាសន៍ ព្រះពុទ្ធសាសនា ទំនៀមទំលាប់ វប្បធម៌ អក្សរសាស្ត្រខ្មែរឱ្យនៅដដែល។ ប៉ុន្តែមុននឹងស្លាប់ លោកឧកញ៉ា **សឺន គុយ** បានសំណូមពរពីរយ៉ាងចំពោះអាជ្ញាធរអាណានិគមវៀតណាមគឺ ១- សូមឱ្យព្រះចៅ ***មិញ ម៉ាង*** (ស្តេចយួន) ប្រកាសលុបរាជបញ្ជានេះជាបន្ទាន់ ហើយប្រកាសប្រាប់ប្រជារាស្ត្រខ្មែរគ្រប់ភូមិស្រុកនៅលើទឹកដីកម្ពុជាក្រោមគ្រប់ៗគ្នាថា ព្រះរាជបញ្ជានេះទុកជាមោឃៈ. ប្រជារាស្ត្រខ្មែរទាំងអស់មានសិទ្ធិសេរីភាពគោរពព្រះពុទ្ធសាសនា និងទំនៀមទំលាប់ខ្មែរតាមធម្មតា ។ ២-មុនពេលយកខ្ញុំទៅសម្លាប់. ទោះបីជានៅកន្លែងណា ឬដោយវិធីណាក៏ដោយ សូមឱ្យខ្ញុំបានជួបមុខប្រជារាស្ត្រខ្មែររបស់ខ្ញុំចំនួនកន្លះម៉ោងដើម្បីសំណេះសំណាល និងផ្តែផ្តាំមុនពេលខ្ញុំស្លាប់ ។ មេទ័ពយួនឈ្មោះ**អុង ឡូវ** បានយល់ព្រមភ្លាមដោយគ្មានរួញរា ។

មួយសប្តាហ៍ក្រោយមក ពួកអាណានិគមវៀតណាមបានរៀបចំពិធីជួបជុំប្រជារាស្ត្រខ្មែរតាមសំណើរបស់លោកឧកញ៉ា **សឺន គុយ** នៅវត្តពោធិសាលរាជកំពង់ (បច្ចុប្បន្នស្ថិតនៅកណ្តាលទីរួមខេត្តព្រះត្រពាំង) ។ លោកឧកញ៉ា**សឺន គុយ** បានមានប្រសាសន៍ផ្តែផ្តាំជាចុងក្រោយទៅកាន់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរ ដែលយើងជាកូនខ្មែរទាំងអស់ត្រូវចងចាំថា" *ខ្ញុំមានក្តីរំភើបចិត្តខ្លាំងណាស់ ដែលបានជួបមុខបងប្អូន និងព្រះសង្ឃយើងមុនពេលខ្ញុំផុតជីវិតនេះ។ ខ្ញុំសូមអភ័យទោសពីសំណាក់បងប្អូននិងព្រះសង្ឃជាទីស្នេហា ដោយខ្ញុំព្រះករុណា ខ្ញុំបាទពុំមានសមត្ថភាពគ្រប់គ្រាន់នឹងបំរើជាតិមាតុភូមិ។ ដូច្នេះខ្ញុំត្រូវតែបញ្ចប់ជីវិតដើម្បីជាតិរស់ ដោយពុំមានស្តាយស្រណោះសោះឡើយ។ ឥឡូវនេះ ទំនៀមទំលាប់ ប្រពៃណី ព្រះពុទ្ធសាសនាខ្មែរ យើងបានទាមទារមកវិញហើយ។ ហេតុនេះសូមបងប្អូនរួមជាតិទាំងអស់ថែរក្សាឱ្យបានគង់វង្សជារៀងរហូត កុំមានថ្ងៃផុតរលត់ឡើយ ។*

*សូមបងប្អូនចងចាំ និងយល់ឱ្យបានច្បាស់ថា ពូជសាសន៍ខ្មែរយើងជាពូជសាសន៍ដែលធ្លាប់ធ្វើមហាអំណាចល្បីល្បាញសុះសាយពាសពេញពិភពលោក។ ហេតុនេះ យើងត្រូវមានស្មារតីរឹងប៉ឹងរួមសាមគ្គីគ្នាជានិច្ច កុំជឿពាក្យចាក់រុកពោកប្រាស់ បំបែកបំបាក់របស់សត្រូវ ឬលក់ក្បាលបំរើនយោបាយឱ្យគេសម្លាប់ជាតិខ្លួនឯង ដោយគិតតែពីប្រយោជន៍ បុណ្យសក្តិ មាសប្រាក់ផ្ទាល់ខ្លួនឱ្យសោះ ។*

*នៅទីបញ្ចប់ខ្ញុំជឿជាក់ថា ខ្ញុំម្នាក់ស្លាប់ទៅ នៅមានបងប្អូនកូនខ្មែរជំនាន់ក្រោយជាច្រើនលាននាក់ទៀត ដែលមានឧត្តមគតិជាតិខ្ពង់ខ្ពស់ ហ៊ានប្តូរជីវិតដើម្បីការពារបូរណភាពទឹកដី សេរីភាព ព្រះពុទ្ធសាសនា និងពូជសាសន៍ឱ្យបានគង់វង្សជាពុំខាន ។"*

ក្រោយពីឧកញ៉ា **សឺន គុយ** បានទទួលមរណភាព ដោយពួកអាជ្ញាធរយួនកាត់កទាំងរស់នៅមុខសាលាខេត្តព្រះត្រពាំងជាថ្នូរប្តូរនិងភាពគង់វង្សពូជសាសន៍ សាសនា វប្បធម៌ខ្មែរកម្ពុជាក្រោមនេះ. ភាពសុខសាន្តរបស់ប្រជារាស្ត្រខ្មែរកម្ពុជា

ក្រោម កើតមានតែមួយរយៈខ្លីប៉ុណ្ណោះ ។ ពួកអាណានិគមយួនចាប់ផ្ដើមអនុវត្តនយោបាយប្រល័យពូជសាសន៍ជាបន្តទៀត និងកាចសាហាវជាងមុន ជាក់ស្ដែងដូចជាសោកនាដកម្មខ្មែរកម្ពុជាក្រោមឆ្នាំ១៨៣៤-១៨៤១ និងឆ្នាំ១៩៤៥-១៩៦០ ពិសេសថ្មីៗនេះនៅឆ្នាំ១៩៨៥-១៩៨៧ អាជ្ញាធរអាណានិគមវៀតណាមបានចាប់ព្រះសង្ឃ និងអ្នកប្រាជ្ញបញ្ញវន្តខ្មែរកម្ពុជាក្រោម រាប់ពាន់នាក់ដាក់ពន្ធនាគារ ធ្វើទារុណកម្មយ៉ាងព្រៃផ្សៃរហូតដល់បាត់បង់ជីវិតរាប់រយនាក់ ក្នុងនោះមានព្រះតេជគុណ**តឹម សាង** សង្ឃនាយកខ្មែរកម្ពុជាក្រោមសុគតក្នុងឆ្នាំ១៩៨៧, ព្រះតេជគុណ**ថាច់ ភោគ** សង្ឃនាយករង, ព្រះតេជគុណ**តឹម តុកចើង** ព្រះមេគណខេត្តព្រះត្រពាំង, ព្រះតេជគុណ**ថាច់ ពេជ្រ**, ព្រះតេជគុណ**ថាច់ រាជ**, ព្រះតេជគុណ**ថាច់ ងស់**, ព្រះតេជគុណ**ថាច់ ភិន**, ព្រះតេជគុណ**ថាច់ ញៀវង**, ព្រះតេជគុណ**ថាច់ សេរី** ព្រះតេជគុណ **ថាច់ អ៊ុក**, ព្រះតេជគុណ **សឺនយូ**, ព្រះតេជគុណ**ថាច់ ថាញ**, ព្រះតេជគុណ**ថាច់ ហាយ**, លោកបណ្ឌិត**ហាញ់ សុវណ្ណ**, **ថាច់ ជុំ**, **ថាច់ ជីវ**, **ថាច់ ផាន** , **ថាច់ គង់**, **ថាច់ កុង**, ។ល។ និង ។ល។ អ្នកដែលត្រូវអាជ្ញាធរអាណានិគមវៀតណាមសម្លាប់ ភាគច្រើនលើសលប់ជាសង្ឃនាយក ព្រះមេគណ អនុគណ ព្រះចៅ អធិការ ព្រះពហូសុត្រ សាស្ត្រាចារ្យ គ្រូបង្រៀន ។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

គណៈអធិបតីជាទីគោរព

បងប្អូនជនរួមជាតិជាទីស្នេហា

រីឯព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ ទោះបីស្ថិតក្នុងកាលៈទេសៈបែបណា ពុំដែលបោះបង់ចោលទឹកដីកម្ពុជាក្រោមម្ដងណាឡើយ គឺនៅតែបន្តការតវ៉ានិងតស៊ូតាមគ្រប់រូបភាព ដើម្បីទាមទារទឹកដីកម្ពុជាក្រោមមកវិញ ដូចជានៅឆ្នាំ១៦៤៥ ព្រះបាទអង្គតូ បានទាមទារកោះក្របី ( ព្រៃនគរ) និងម៉ុយស៊ុយ និងនៅ ឆ្នាំ១៦៥៣ បានទាមទារទឹកដីនេះម្ដងទៀត ។ ឆ្នាំ១៧៣៨-១៧៤៧ ក្នុងរជ្ជកាលព្រះបាទធម្មរាជាអង្គសូ, ឆ្នាំ១៧៧៦ ក្នុងរជ្ជកាលព្រះបាទរាមរាជាអង្គទន់ ពិសេសក្នុងរជ្ជកាលព្រះបាទអង្គឌួង ព្រះអង្គបានតស៊ូយ៉ាងប្អូរផ្ដាច់បំផុត ទាំងផ្នែកយោធា ទាំងផ្នែកការទូតដើម្បីដណ្ដើមយកទឹកដីកម្ពុជាក្រោមមកវិញ ។ ព្រះបាទអង្គឌួងបានផ្ញើចុតហ្មាយពីរលើកជូនអធិរាជណាប៉ូឡេអុងទីIII: មួយច្បាប់ផ្ញើនៅខែវិច្ឆិកា ឆ្នាំ១៨៥៣ និងមួយច្បាប់ទៀតផ្ញើនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៨៥៦ ។

ក្នុងព្រះរាជសារលើកទី១ ព្រះករុណា ព្រះបាទអង្គឌួងដ៏មហិមាបានបង្ហាញថ្វាយស្ដេចណាប៉ូឡេអុងទី III នូវមិត្តភាពដ៏ស្មោះរបស់ព្រះអង្គ និងស្នើសុំស្ដេចណាប៉ូឡេអុងនូវជំនួយយោធា ដើម្បីការពារព្រះរាជាណាចក្រកម្ពុជា និងដណ្ដើមយកមកវិញនូវទឹកដីដែលយួនបានឈ្លានពានទន្ទ្រានយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ រាជសារលើកទី២ ព្រះបាទអង្គឌួងបានបញ្ជាក់ប្រាប់ស្ដេចណាប៉ូឡេអុងទីIII នៃប្រទេសបារាំងអំពីសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានៅលើទឹកដីកម្ពុជាក្រោម និងបានស្នើអធិរាជណាប៉ូឡេអុង កុំទទួលយកទឹកដីនៃផ្នែកណាមួយដែលស្ដេចយួនបានប្លន់យកពីព្រះរាជាណាចក្រខ្មែរជូននោះឱ្យសោះ ។ ព្រះរាជសារទាំងពីរច្បាប់នេះបានបញ្ជាក់គ្រប់គ្រាន់ផ្នែកគតិយុត្តិស្ដីពីសិទ្ធិស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជានៅលើទឹកដីកម្ពុជាក្រោម ។

ដូច្នេះការកាត់ ការផ្ទេរ ឬសន្ធិសញ្ញា កិច្ចព្រមព្រៀង ឬច្បាប់អ្វីក៏ដោយ ដែលធ្វើឡើងជាឯកតោភាគី ឬទ្វេភាគី រវាងបារាំង និងវៀតណាមអំពីទឹកដីកម្ពុជាក្រោមសុទ្ធតែខុសច្បាប់ទាំងអស់ ។

នៅឆ្នាំ១៨៦៤ ព្រះករុណាព្រះបាទនរោត្តម បានបំពេញព្រះរាជបេសកកម្មផ្ទាល់ព្រះអង្គ គឺព្រះអង្គបានយាងទៅកាន់ទីក្រុងព្រៃនគរ ដើម្បីចរចាជាមួយមន្ត្រីជាន់ខ្ពស់បារាំងឱ្យប្រគល់ទឹកដីកម្ពុជាក្រោមមកព្រះរាជាណាចក្រកម្ពុជា។ ព្រះករុណាព្រះបាទនរោត្តម ទទួលបាននូវការសន្យាយ៉ាងជាក់លាក់ពីមន្ត្រីជាន់ខ្ពស់បារាំងនៅទីក្រុងព្រៃនគរចំពោះបញ្ហានេះ ។ ព្រះអង្គបានយាងនិវត្តន៍មកព្រះរាជាណាចក្រកម្ពុជាវិញនៅខែតុលាឆ្នាំ១៨៦៤ ប្រកបដោយព្រះរាជហឫទ័យសប្បាយរីករាយនិងសង្ឃឹមជឿជាក់ថា បារាំងនឹងប្រគល់ទឹកដីកម្ពុជាក្រោមមកព្រះរាជាណាចក្រកម្ពុជានៅពេលដ៏ខ្លីខាងមុខ។ តែទីបំផុតបារាំងបែរជាធ្វើព្រងើយដោយរកលេសនេះ លេសនោះមិនចេះអស់មិនចេះហើយ ។

ដើម្បីបង្ហាញសាធារណមតិជាតិ-អន្តរជាតិឱ្យឃើញច្បាស់អំពីជំហររបស់ព្រះរាជាណាចក្រកម្ពុជា មិនព្រមលះបង់សិទ្ធិស្របច្បាប់នៅលើដែនដីកម្ពុជាក្រោម, ព្រះមហាវីរក្សត្រព្រះបាទនរោត្តម សីហនុ បានបំពេញបូជនីយកិច្ចជូនជាតិមាតុភូមិដ៏ធំធេងក្រៃលែង ។ ក្នុងរជ្ជកាលព្រះអង្គពីឆ្នាំ១៩៤១-២០០៤ ព្រះអង្គមិនត្រឹមតែរៀបចំព្រះរាជាណាចក្រកម្ពុជាមួយដ៏ល្បីរន្ទឺលើសកលលោកទេ តែព្រះអង្គបានធ្វើឱ្យសហគមន៍អន្តរជាតិ និងអ្នកកត់ត្រាប្រវត្តិសាស្ត្រនានាយល់យ៉ាងច្បាស់ថា ព្រះមហាក្សត្រខ្មែរមិនព្រមលះបង់សិទ្ធិរបស់ខ្លួននៅលើទឹកដីកម្ពុជាក្រោមទៀតផង ។

នៅក្នុងព្រះរាជសារចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ផ្ញើជូនអធិរាជជប៉ុន, ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជាលើដែនដីកម្ពុជាក្រោម ដោយបានរំលឹកអំពីព្រះរាជសាររបស់ព្រះបាទព្រះអង្គឌួង ដែលបានផ្ញើជូនអធិរាជណាប៉ូឡេអុងទីIII ហើយក៏បានស្នើបង្កើតគណៈកម្មការចំរុះមួយដើម្បីកំណត់ព្រំដែនខ្មែរយួន។

ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៤៨ ព្រះអង្គបានផ្ញើព្រះរាជសារមួយច្បាប់ជូនលោកស្នងការជាន់ខ្ពស់បារាំងនៅឥណ្ឌូចិន ដោយបញ្ជាក់អំពីសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានៅលើទឹកដីកម្ពុជាក្រោម ហើយព្រះអង្គត្រូវតែដឹងឮអំពីការចរចា ឬការចុះសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងផ្សេងៗរវាងបារាំង និងវៀតណាម ។

ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ បានប្រឆាំងដាច់ខាតចំពោះកិច្ចព្រមព្រៀងរវាងបារាំងនិងវៀតណាមនៅឆកសមុទ្រហាឡុង ដែលជាគោលការណ៍ទទួលស្គាល់ភាគ (KY) ទាំង៣របស់វៀតណាមគឺ Bac Ky វៀតណាមខាងជើង(ប្រទេសយួន), Trung Ky ប្រទេសចម្ប៉ា (វៀតណាមកណ្តាល) និង Nam Ky កម្ពុជាក្រោម(វៀតណាមខាងត្បូង)។ ការទទួលបែបនេះមានន័យថា ទទួលស្គាល់ទឹកដីកម្ពុជាក្រោមជាទឹកដីរបស់យួន។ ដូចនេះ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ជាទីសក្ការៈនៃយើងបានបដិសេធហើយចាត់ទុកកិច្ចព្រមព្រៀងនោះជាមោឃៈតាមព្រះរាជសារចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៤៩ ។

នៅថ្ងៃទី២២ កញ្ញា ឆ្នាំ១៩៦១ព្រះអង្គបានថ្លែងនៅអង្គការសហប្រជាជាតិក្នុងសម័យប្រជុំលើកទី១៦ តវ៉ាប្រឆាំងនិងការកាត់ទឹកដីខ្មែរ ( កម្ពុជាក្រោម ) តាមកិច្ចព្រមព្រៀងបារាំង-យួនឆ្នាំ១៩៤៨ និងច្បាប់បារាំងឆ្នាំ១៩៤៩ ហើយបាន



www.khmerkromngo.org

បញ្ជាក់យ៉ាងច្បាស់ថា តាមគតិយុត្តិ ទឹកដីកម្ពុជាក្រោមនៅតែជាកម្មសិទ្ធិស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ មិនតែប៉ុណ្ណោះនៅរាល់សន្និសីទអន្តរជាតិ ស្តីពីបញ្ហាកម្ពុជា ព្រះរាជតំណាងរាជរដ្ឋាភិបាលរបស់ព្រះអង្គតែងតែលើកយកបញ្ហាកម្ពុជាក្រោមមកភ្ជាប់ជានិច្ច ។

ដើម្បីប្រឆាំងនិងច្បាប់លេខ៤៩-៧៣៣ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ របស់បារាំងកាត់ទឹកដីកម្ពុជាក្រោមឱ្យវៀតណាមនោះ, កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៣ សហគមន៍ខ្មែរកម្ពុជាក្រោមបានផ្ញើលិខិតជូនរដ្ឋ សភាព្រឹទ្ធសភា និងរដ្ឋាភិបាលបារាំង ស្នើធ្វើច្បាប់ថ្មីលុបច្បាប់លេខ៤៩-៧៣៣ ពីព្រោះវាជាច្បាប់ដ៏អយុត្តិធម៌ចំពោះប្រជារាស្ត្រខ្មែរ។ លិខិតជាផ្លូវការនោះ សហគមន៍ខ្មែរកម្ពុជាក្រោមក៏បានស្នើសុំការគាំទ្រពីព្រះមហាក្សត្រ ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលខ្មែរដែរ។ ប៉ុន្តែគួរឱ្យសោកស្តាយមានតែព្រះមហាក្សត្រខ្មែរ ព្រះបាទសម្តេចព្រះនរោត្តម សីហនុតែមួយព្រះអង្គគត់ដែលបានគាំទ្រសំណើនេះ តែព្រះអង្គទ្រង់ប្រទានព្រះរាជតម្រិះថាសុំឱ្យរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលខ្មែរចុះហត្ថលេខារួមគ្នាជាមួយនិងព្រះអង្គ។ ប៉ុន្តែរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលគ្មានផ្តល់ចម្លើយអ្វីឡើយរហូតមកដល់ពេលនេះ ។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៣ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានមានព្រះរាជបន្ទូលនៅក្នុងព្រះរាជសារមួយច្បាប់បញ្ជាក់ជូនជនរួមជាតិថា “ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាបន្តបន្ទាប់ និងនរោត្តម សីហនុ មិនដែលប្រគល់ទឹកដីមាតុភូមិកម្ពុជា សូម្បីតែមួយចំអាមជូនទៅវៀតណាម ថៃ ឬឡាវនោះទេ ។ នៅក្នុងសម័យណាក៏ដោយប្រទេសវៀតណាម ប្រទេសថៃ ប្រទេសឡាវ មិនដែលមានគុណអ្វីមកលើព្រះរាជាណាចក្រកម្ពុជា ហើយមហាក្សត្រខ្មែរ និងនរោត្តម សីហនុមិនដែលក្បត់ជាតិ ប្រជារាស្ត្រ មាតុភូមិកម្ពុជាម្តងណាឡើយ ”។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៥ ព្រះមហាវីរក្សត្រព្រះបាទសម្តេចព្រះនរោត្តម សីហនុ បានមានព្រះរាជបន្ទូលនៅក្នុងព្រះរាជសារមួយច្បាប់មានជាអាទិ៍ថា ការកាត់ទឹកដីខ្មែរកម្ពុជាក្រោមទៅឱ្យវៀតណាមនៅឆ្នាំ១៩៤៩នោះ ជាការខុសច្បាប់ និងអយុត្តិធម៌បំផុត យ៉ាងហោចណាស់ក៏អាណានិគមបារាំងត្រូវប្រគល់ទឹកដីកម្ពុជាក្រោម៥០ភាគរយមកឱ្យព្រះរាជាណាចក្រកម្ពុជាដែរ ។

ព្រះមហាវីរក្សត្រ ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ជាព្រះមហាក្សត្រខ្មែរស្នេហាជាតិដ៏ខ្ពង់ខ្ពស់មួយអង្គគួរជាទីសក្ការៈបំផុត។ ព្រះអង្គបានផ្តល់នូវភាពកក់ក្តៅដល់ការតស៊ូរបស់ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោមគ្រប់ពេលវេលា, ព្រះអង្គនៅតែគិតគូរពីសុខទុក្ខប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលជាកូន ចៅ ចៅទួតរបស់ព្រះអង្គជានិច្ចមិនដែលបំភ្លេចម្តងណាឡើយ ។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

គណៈអធិបតីជាទីគោរព

បងប្អូនជនរួមជាតិជាទីស្នេហា

ការប្រារព្ធពិធីបុណ្យឆ្នាំនេះ ស្របពេលដែលអាជ្ញាធរអាណានិគមវៀតណាមកំពុងចាប់ផ្សឹកព្រះសង្ឃខ្មែររហូតដល់១៦អង្គ និង៩អង្គត្រូវតុលាការវៀតណាមខេត្តឃ្លាំង (សុកត្រាំង) កាត់ទោសដាក់ពន្ធនាគារពី២ឆ្នាំដល់៤ឆ្នាំយ៉ាងអយុត្តិធម៌



www.khmerkromngo.org

បំផុត ។ ព្រះសង្ឃទាំងនោះពុំមានកំហុសអ្វីទាល់តែសោះ គ្រាន់តែនិមន្តចូលរួមធ្វើបាតុកម្មទាមទារសិទ្ធិសេរីភាពក្នុងការសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ និងសេរីភាពជំនឿសាសនាប៉ុណ្ណោះ ។ បច្ចុប្បន្ន ស្ថានភាពនៃប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកំពុងតែធ្លាក់ទៅក្នុងស្ថានភាពមួយដ៏ធ្ងន់ធ្ងរគួរឱ្យបារម្ភ ដែលអាជ្ញាធរអាណានិគមវៀតណាមបានហាមផ្តាច់ក្នុងការទាក់ទងពីវត្តមួយទៅវត្តមួយ ការជួបប្រជុំគ្នា និងហាមមិនឱ្យព្រះសង្ឃនិមន្តបិណ្ឌបាត្រជាដើម ។

តាមរយៈវេទិកាថ្ងៃនេះ សហគមន៍ខ្មែរកម្ពុជាក្រោមទូទាំងពិភពលោក សូមអំពាវនាវរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយធ្វើអន្តរាគមន៍ជាបន្ទាន់ និងសូមអំពាវនាវអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសស្រឡាញ់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សទាំងអស់ដាក់ការគាបសង្កត់ឱ្យបានខ្លាំងក្លា ដើម្បីបង្ខំឱ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមដោះលែងព្រះសង្ឃដែលកំពុងជាប់ឃុំឃាំងក្នុងពន្ធនាគារ ហើយបំបួសព្រះសង្ឃទាំង១៦អង្គឡើងវិញ ពិសេសបញ្ឈប់ជាបន្ទាន់នូវការធ្វើទុក្ខបុកម្នេញ សម្លុតគំរាម និងការបិទសិទ្ធិសេរីភាពសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ និងជំនឿ សាសនា នៅលើទឹកដីកម្ពុជាក្រោម។

ភាពគង់វង្សពូជសាសន៍ វប្បធម៌ អក្សរសាស្ត្រ ទំនៀមទំលាប់ ប្រពៃណី និងពុទ្ធសាសនាខ្មែរកម្ពុជាក្រោមរហូតមកដល់សព្វថ្ងៃ គឺដោយសារការតស៊ូប្តូរជីវិតរាប់លាននាក់នៃខេមរកុលបុត្រជាទីស្នេហា តែមិនមែនដោយសារយួនដាក់ទានឱ្យយើងទេ ។ នេះជាគុណបំណាច់មិនអាចកាត់ថ្លៃបានរបស់បុព្វបុរសយើងដែលបានលះបង់សាច់ស្រស់ឈាមស្រស់តស៊ូក្នុងបុព្វហេតុទឹកដីនិងពូជសាសន៍ខ្មែរកម្ពុជាក្រោម ។ យើងទាំងអស់គ្នាត្រូវចងចាំថាយើងជាខ្មែរមិនមានវត្តមាននៅទីនេះក្តីនិងជនរួមឈាមខ្មែរនៅលើទឹកដីកម្ពុជាក្រោមក្តី ដែលត្រូវសហគមន៍ជាតិ និងអន្តរជាតិទទួលស្គាល់ថាជាខ្មែរ ឬខ្មែរកម្ពុជាក្រោម មានវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីជាខ្មែរពូជពង្សអង្គរតែមួយនោះ គឺដោយសារការតស៊ូប្តូរជីវិតរាប់លាននាក់របស់ជនរួមឈាមខ្មែរកម្ពុជាក្រោម។

ដូច្នេះ ដើម្បីសំដែងនូវការគោរពនិងដឹងគុណចំពោះគុណូបការៈដ៏ថ្លៃថ្លារបស់ព្រះមហាវីរក្សត្រ ព្រះវីរសមណៈ និងវីរបុរស វីរនារីដ៏ជាទីគោរពសក្ការៈនៃយើងទាំងអស់គ្នា, ថ្ងៃនេះសហគមន៍ខ្មែរកម្ពុជាក្រោម និងអង្គការ សមាគមខ្មែរកម្ពុជាក្រោមរៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១,៩៤៩អង្គ ឧទ្ទិសកុសលប្រគេន ថ្វាយ និងជូនព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ ព្រះវីរសមណៈ និងវីរបុរស-វីរនារីខ្មែរទាំងអស់ដែលបានតស៊ូបូជាជីវិត ក្នុងបុព្វហេតុពូជសាសន៍ សាសនា និងទឹកដីខ្មែរទាំងមូល ពិសេសទឹកដីកម្ពុជាក្រោម។ ពិធីនេះក៏ជាការប្រារព្ធទិវាកាន់ទុក្ខខួបគំរប់៥៨ឆ្នាំនៃថ្ងៃអាណានិគមបារាំងកាត់ទឹកដីកម្ពុជាក្រោមឱ្យអាជ្ញាធរអាណានិគមវៀតណាមដែរ ។

ការតបស្នងសងគុណបុព្វបុរសរបស់យើង ដោយធ្វើបុណ្យសុន្ទរទានតាមប្រពៃណីព្រះពុទ្ធសាសនា នៅមិនទាន់គ្រប់គ្រាន់នៅឡើយ ។ ដូច្នេះដើម្បីឱ្យបុព្វបុរសយើងស្ងប់ចិត្ត បិទភ្នែកជិត យើងជាខ្មែរគ្រប់រូប ពិសេសគឺកម្ពុជាក្រោមត្រូវតែសងគុណបុព្វបុរសរបស់យើងដោយឧត្តមគតិស្នេហាជាតិ ដោយកាយ វាចា ចិត្តឱ្យបានព្រមៗគ្នាពិតប្រាកដ។

មុននឹងបញ្ចប់ តាងនាមប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម, តាងនាមគណៈកម្មការរៀបចំបុណ្យ និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ សូមព្រះបរមរាជានុញ្ញាតថ្លែងនូវអំណរព្រះមហាករុណាធិគុណយ៉ាងជ្រាលជ្រៅបំផុត ថ្វាយ**ព្រះករុណា ព្រះ**

**បាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រោសព្រះរាជទាន ***ព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សនារី មុនីពង្ស*** ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ធ្វើជាអធិបតីក្នុងពិធីបុណ្យជាប្រវត្តិសាស្ត្រនេះ ។ នេះជាការបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីការយកព្រះទ័យទុកដាក់ និងអាណិតអាសូរដល់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមដ៏ពិតប្រាកដ ហើយជាការបន្តប្រពៃណីព្រះមហាក្សត្រមុនៗ ពិសេសព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ដែលតែងតែលើកទឹកចិត្ត និងផ្តល់នូវការគាំទ្រដល់សកម្មភាពតស៊ូស្របច្បាប់របស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជានិច្ច ។

ជាមួយគ្នានេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតថ្លែងអំណរព្រះមហាករុណាទិគុណយ៉ាងជ្រាលជ្រៅថ្វាយ**ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី ឯកភាពជាតិខ្មែរ និងព្រះមហាក្សត្រិយានី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេចក្តីថ្លៃថ្នូរ និងសុភមង្គល** ដែលបានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យផ្ទាល់ចំនួន ២,០០០ដុល្លាសហរដ្ឋអាមេរិក និង**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យផ្ទាល់ចំនួន១,០០០ដុល្លាសហរដ្ឋអាមេរិក ដើម្បីរៀបចំពិធីបុណ្យនេះ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជនទាំងអស់ ទាំងបងប្អូនរួមឈាមនៅឯនាយសមុទ្រទាំងនៅព្រះរាជាណាចក្រកម្ពុជា ដែលបានជួយឧបត្ថម្ភការរៀបចំពិធីបុណ្យឱ្យប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ព្រះតេជគុណគ្រប់ព្រះអង្គ ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ និងបងប្អូនជនរួមឈាមទាំងអស់ដែលបាននិមន្តនិងអញ្ជើញចូលរួមក្នុងពិធីបុណ្យយ៉ាងអធិកអធម ។

ដោយឥដ្ឋមនុញ្ញផលដែលកើតអំពីកតញ្ញូកតវេទិតាធម៌នេះ ទូលព្រះបង្គំជាខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រៃ និងវត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រ ជួយបីបាច់ថែរក្សា**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាវីរក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ព្រមទាំងព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរជាកូន ចៅចៅទួតរបស់ព្រះអង្គជាយូរអង្វែងតរៀងទៅ និងសូមថ្វាយព្រះពរ**ព្រះអង្គម្ចាស់ក្សត្រីយ៍ស៊ីសុវត្ថិពង្សនារី មុនីពង្ស ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាព្រះអធិបតីក្នុងពិធីបុណ្យ និងគោរពប្រគេនពរ និងជូនពរព្រះសង្ឃ ព្រមទាំងប្រជារាស្ត្រខ្មែរទាំងអស់សូមទទួលបាននូវសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ដូចមនុស្សជាតិនានានៅលើសកលលោក ព្រមទាំងបានប្រកបដោយពុទ្ធពរទាំងឡាយ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

*សូមអរព្រះគុណ និងអរគុណ*

# THE KHMER KAMPUCHEA KROM COMMUNITY



ព្រះអង្គម្ចាស់ក្សត្រិយ ស៊ី សុវត្ថិ ពង្សនារី មុនីពង្ស ព្រះរាជតំណាង
ដ៏ខ្ពង់ខ្ពស់ព្រះករុណាព្រះបាទ សម្តេចព្រះ បរមនាថ នរោត្តម សីហមុនី

